**សុន្ទរកថា**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ក្នុងពិធីបើកវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល**

ថ្ងៃព្រហស្បតិ៍ ០៩ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨

**-គណៈអធិបតី**

**-ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិក សមាជិកានៃអង្គវេទិកាទាំងមូល!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកចូលរួមជាមួយនឹង ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនាឱកាសដ៏ថ្លៃថ្លានេះ។

ក្នុងនាមរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះវត្តមានដ៏ឧត្តុង្គឧត្តមរបស់គណៈអធិបតី ភ្ញៀវកិត្តិយស សមាជិក សមាជិកានៃអង្គវេទិកាទាំងមូល ដែលបានឆ្លៀតពេលវេលាដ៏មមាញឹកដើម្បីចូលរួមក្នុងវេទិកានាឱកាសដ៏មហាឡោរិកនេះ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងនាមរាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ ខ្ញុំសូមអនុញ្ញាតធ្វើការគូសបញ្ជាក់ពីប្រវត្តិដោយសង្ខេបនៃដំណើរការវិវឌ្ឍន៍ស្ថានភាពនយោបាយនៅកម្ពុជាជូនអង្គវេទិកាដូចតទៅ៖

បន្ទាប់ពីប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមស៊ីវិលបំផ្លិចបំផ្លាញអស់រយៈពេលប្រមាណជាង ០២ទស្សវត្ស ភាគីជម្លោះទាំងអស់បានងាកមករកតុចរចារ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស កាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ និងបានរៀបចំឲ្យមានការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ លើកដំបូងនៅឆ្នាំ១៩៩៣ ដោយអង្គការសហប្រជាជាតិ ព្រមទាំងបានបង្កើតរដ្ឋធម្មនុញ្ញថ្មីមួយនាឆ្នាំ១៩៩៣ ដែលកំណត់អំពីរបបប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា។ ទោះបីជាមានការរៀបចំការបោះឆ្នោតនៅឆ្នាំ១៩៩៣ ក៏ដោយ ប្រទេសកម្ពុជានៅតែមិនទាន់ទទួលបានសុខសន្តិភាពពេញលេញទូទាំងប្រទេសនៅឡើយ រហូតដល់ចុងឆ្នាំ១៩៩៨ ទើបកម្ពុជាទទួលបានសុខសន្តិភាពពេញផ្ទៃប្រទេស តាមរយៈគោលនយោបាយឈ្នះ-ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ ដូច្នេះ កិច្ចការអាទិភាពរបស់រាជរដ្ឋាភិបាលក្រោយពីការបោះឆ្នោតជាតិនាឆ្នាំ១៩៩៣ គឺការរួបរួមគ្នាកសាងជាតិតាមរយៈការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងការស្តារហេដ្ឋារចនាសម្ព័ន្ធដែលត្រូវបានបំផ្លាញ

ដោយសារសង្គ្រាមឡើងវិញ។ រហូតមកដល់បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានការអភិវឌ្ឍលើគ្រប់វិស័យ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តខ្វាត់ខ្វែង និងមានកំណើនសេដ្ឋកិច្ចដ៏រឹងមាំមួយក្នុងចំណោមប្រទេសនានាក្នុងតំបន់ និងពិភពលោក ជាពិសេសនៅក្នុងឆ្នាំ២០១៧ កន្លងទៅនេះ កម្ពុជាសម្រេចបាននូវអត្រាកំណើនសេដ្ឋកិច្ចប្រមាណ ៧,១% ហើយនៅឆ្នាំ២០១៨នេះ ត្រូវបានប៉ាន់ប្រមាណថានឹងសម្រេចបានអត្រាកំណើនក្នុងរង្វង់ ៧%។ ការសម្រេចបាននូវអត្រាកំណើនសេដ្ឋកិច្ចជាប់ៗគ្នា ក្នុងរយៈពេលជិត ០២ទស្សវត្សនេះ បានធ្វើឲ្យកម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

ឆ្លងតាមបទពិសោធន៍កន្លងមក រួមជាមួយនឹងសមិទ្ធផលខាងលើនេះ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ ដោយត្រូវធានាឲ្យបាននូវសុខសន្តិភាពពេញផ្ទៃប្រទេសទោះក្នុងតម្លៃណាក៏ដោយ ដើម្បីបន្តនិរន្តរភាពនៃការរីកចម្រើន និងការអភិវឌ្ឍ។

រាជរដ្ឋាភិបាលកម្ពុជាក៏បានទទួលស្គាល់ផងដែរថា ការរីកចម្រើន និងការអភិវឌ្ឍរហូតដល់ពេលនេះ គឺពិតជាមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងនោះមានដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការសង្គមស៊ីវិល។ អង្គការសង្គមស៊ីវិលទាំងក្នុងស្រុក និងបរទេសបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ និងគាំទ្រដល់សេវាសង្គមនៅតាមមូលដ្ឋានជនបទ និងសហគមន៍ដាច់ស្រយាល និងធ្វើសកម្មភាពនៅគ្រប់រាជធានី ខេត្ត ក្នុងវិស័យសំខាន់ៗដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ច សង្គម នៅក្នុងប្រទេសកម្ពុជា។ អង្គការសង្គមស៊ីវិល ក៏បានចូលរួមផងដែរក្នុងការតស៊ូមតិឲ្យមានកំណែទម្រង់ជាតិ ដើម្បីលើកកម្ពស់សុខភាព ការអប់រំ អភិបាលកិច្ច សិទ្ធិមនុស្ស ប្រព័ន្ធច្បាប់ សេវាសង្គម បរិស្ថាន សុខុមាលភាពស្ត្រី និងកុមារ នេះបើយោងតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីស្តីពីសង្គមស៊ីវិលនៅកម្ពុជា កាលពីឆ្នាំ២០១១។

**-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ដូចដែលខ្ញុំបានជម្រាបជូនខាងលើ ព្រះរាជាណាចក្រកម្ពុជាយើងអនុវត្តនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស បើផ្អែកតាមមាត្រា៥១ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ នៅក្នុងសង្គមប្រជាធិបតេយ្យ អង្គការសង្គមស៊ីវិល និងគណបក្សនយោបាយ គឺជាកោសិកាដ៏សំខាន់មួយដែលមិនអាចខ្វះបាន។ ដូច្នេះ ដើម្បីធានាការអនុវត្តនូវសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចូលរួមកិច្ចដំណើរការលទ្ធិប្រជាធិបតេយ្យ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ត្រង់មាត្រា៤២ កថាខណ្ឌទី១ ដែលបានចែងថា "ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ" ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានរៀបចំឡើង និងដាក់ឲ្យប្រើប្រាស់នៅចុងឆ្នាំ២០១៥ ដោយឈរលើមូលដ្ឋានរដ្ឋធម្មនុញ្ញ រួមទាំងច្បាប់នានាជាធរមាន និងលើមូលដ្ឋាននៃមាត្រា២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងមាត្រា១៥ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអនុញ្ញាតរៀបរាប់ដោយសង្ខេបអំពីដំណើរការរៀបចំតាក់តែងច្បាប់នេះឡើង។ នាពាក់កណ្តាលឆ្នាំ១៩៩៥ ក្រសួងមហាផ្ទៃបានផ្តួចផ្តើមរៀបចំសេចក្តីព្រាងច្បាប់ស្តីពី

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយមានកិច្ចសហការជាមួយក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័ននានា និងមានការគាំទ្របច្ចេកទេសពីអ្នកជំនាញការច្បាប់ អង្គការអន្តរជាតិ និងអ្នកជំនាញការបរទេសមួយចំនួន រួចហើយបានយកសេចក្តីព្រាងច្បាប់នេះទៅពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា។

ក្នុងការពិគ្រោះយោបល់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានគាំទ្រក្នុងការរៀបចំឲ្យមានច្បាប់នេះ និងមួយចំនួនទៀតបានផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាលឲ្យពន្យារការរៀបចំសេចក្តីព្រាងច្បាប់នេះមួយរយៈពេលសិន។ រាជរដ្ឋាភិបាល បានគោរពតាមអនុសាសន៍របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលស្នើសុំពន្យារការអនុម័តច្បាប់នេះ រហូតដល់ដើមឆ្នាំ២០១១ ទើបរាជរដ្ឋាភិបាលលើកយកសេចក្តីព្រាងច្បាប់នេះមកធ្វើការពិនិត្យកែសម្រួលឡើងវិញ ដោយផ្អែកលើអនុសាសន៍ពីអ្នកពាក់ព័ន្ធនានា គួបផ្សំនឹងការសិក្សាស្រាវជ្រាវបទពិសោធន៍ពីប្រទេសនានាក្នុងតំបន់ និងលើសកលលោក រួមមានប្រទេសអូស្ត្រាលី ជប៉ុន ចិន ឥណ្ឌា សិង្ហបុរី ថៃ រុស្សី សហរដ្ឋអាមេរិក និងប្រទេសបារាំង។ ក្នុងអំឡុងខែមករា ឆ្នាំ២០១១ រាជរដ្ឋាភិបាលបានរៀបចំឲ្យមានសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់នេះ ដោយមានតំណាងសមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស និងអ្នកពាក់ព័ន្ធនានាចូលរួម ព្រមទាំងបានជួបពិភាក្សាដោយឡែកៗជាមួយតំណាងស្ថានទូតនានាប្រចាំកម្ពុជា អង្គការអន្តរជាតិ សមាគម អង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗមួយចំនួន ដើម្បីប្រមែប្រមូលអនុសាសន៍បន្ថែមទៀត រួចហើយបានពិនិត្យកែសម្រួលសេចក្តីព្រាងច្បាប់នេះ ដើម្បីដាក់ជូនសិក្ខាសាលាពិគ្រោះយោបល់ជាលើកទី២ ក្នុងអំឡុងខែធ្នូ ឆ្នាំ២០១១។

ទោះបីជារាជរដ្ឋាភិបាលបានខិតខំកែលម្អសេចក្តីព្រាងច្បាប់នេះ ផ្អែកលើអនុសាសន៍ដូចបានជម្រាបជូនខាងលើក៏ដោយ ក៏មានមតិមួយចំនួនបានផ្តល់អនុសាសន៍ស្នើឲ្យពន្យារពេលអនុម័តសេចក្តីព្រាងច្បាប់នេះមួយរយៈពេលជាបន្តទៀត។ ផ្អែកលើសំណូមពរនេះ រាជរដ្ឋាភិបាលក៏បានបន្តពន្យារពេលក្នុងការអនុម័តលើសេចក្តីព្រាងច្បាប់តាមយោបល់របស់សមាគម អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ជាលើកទី២។ ក្នុងរយៈពេលនេះ ក្រុមការងាររាជរដ្ឋាភិបាល បានបន្តពិនិត្យកែលម្អសេចក្តីព្រាងច្បាប់នេះជាបន្តបន្ទាប់រហូតដល់ពាក់កណ្តាលឆ្នាំ២០១៥ ទើបសម្រេចដាក់ជូនសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥។ បន្ទាប់ពីទទួលបានការអនុម័តពីគណៈរដ្ឋមន្ត្រី សេចក្តីព្រាងច្បាប់នេះត្រូវបានគណៈកម្មការជំនាញនៃរដ្ឋសភាសហការជាមួយតំណាងរាជរដ្ឋាភិបាល រៀបចំឲ្យមានសិក្ខាសាលាពិគ្រោះយោបល់កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ដោយមានអ្នកពាក់ព័ន្ធនានាចូលរួមចំនួន ៥៤០រូប ដើម្បីប្រមូលអនុសាសន៍បន្ថែមទៀត ក្នុងគោលបំណងធ្វើការកែលម្អនូវសេចក្តីព្រាងច្បាប់នេះ ឲ្យកាន់តែមានភាពល្អប្រសើរថែមទៀត។

សរុបមក ច្បាប់នេះត្រូវបានរៀបចំឡើងលើមូលដ្ឋាននៃរដ្ឋធម្មនុញ្ញ និងច្បាប់នានាជាធរមាននៅកម្ពុជា រួមនឹងលិខិតតូបករណ៍អន្តរជាតិដែលកម្ពុជាយើងបានទទួលស្គាល់ ព្រមទាំងបទពិសោធន៍

នានាជាអន្តរជាតិ ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ជាច្រើនដំណាក់កាល ស្របតាមដំណើរការ និងគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ដោយចំណាយរយៈពេលប្រមាណជាង២០ឆ្នាំ។

ជាការពិត ច្បាប់នេះត្រូវបានរៀបចំឡើងក្នុងគោលបំណងធានាការពារសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ និងផលប្រយោជន៍សាធារណៈ ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាមួយអាជ្ញាធរសាធារណៈ ដើម្បីអភិវឌ្ឍសង្គមកម្ពុជាឲ្យមានការរីកចម្រើនលើគ្រប់វិស័យ ដូចមានចែងក្នុងមាត្រា១ និងមាត្រា ២ នៃច្បាប់នេះ។ ទន្ទឹមនេះ ច្បាប់នេះមិនមានវិសាលភាពគ្របដណ្តប់លើសហគមន៍តូចៗនៅមូលដ្ឋាន ដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយដែលប្រជាពលរដ្ឋរួមគ្នាបង្កើតឡើងក្នុងគោលដៅជួយគ្នាទៅវិញទៅមកនៅក្នុងមូលដ្ឋានរបស់ខ្លួន ឬការពារផលប្រយោជន៍របស់សហគមន៍នានានៅតាមមូលដ្ឋាននោះឡើយ។

សូមបញ្ជាក់ថា បន្ទាប់ពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានប្រកាសឲ្យប្រើកាលពីចុងឆ្នាំ២០១៥ មានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន **៦៨៣** បន្ថែមទៀតបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ។ រហូតមកដល់បច្ចុប្បន្ននេះ មានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ សរុបចំនួន**៥៣២៨** ដែលក្នុងនោះសមាគម មានចំនួន **២១៧៩** និងអង្គការមិនមែនរដ្ឋាភិបាល មានចំនួន**៣១៤៩**។ តាមរយៈតួលេខនេះ បានបញ្ជាក់ឲ្យឃើញថា សិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មិនមាននិន្នាការថយចុះ ដូចការលើកឡើងរបស់មជ្ឈដ្ឋានជាតិ និងអន្តរជាតិមួយចំនួននោះឡើយ។

**-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

រាជរដ្ឋាភិបាលកម្ពុជានៅតែចាត់ទុកអង្គការសង្គមស៊ីវិល គឺជាដៃគូមិនអាចខ្វះបានក្នុងការរួមចំណែកអភិវឌ្ឍជាតិ និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ជាក់ស្តែង ខ្ញុំសូមអនុញ្ញាតគូសបញ្ជាក់អំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលក្នុងនោះគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កាលពីឆ្នាំ២០១៣ បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ក្នុងការធានាបាននូវគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការអនុវត្តការងារគណនេយ្យភាពសង្គមនឹងធានាបានថា ព័ត៌មាននានាពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាលឃុំ សង្កាត់ ការបំពេញការងាររបស់សាលាបឋមសិក្សា និងមណ្ឌលសុខភាព សិទ្ធិ ស្តង់ដារ និងបញ្ហាហិរញ្ញវត្ថុត្រូវបានផ្តល់ជូនប្រជាពលរដ្ឋក្នុងលក្ខណៈសាមញ្ញ ងាយយល់ និងបង្កលក្ខណៈឱ្យប្រជាពលរដ្ឋទទួលបានព័ត៌មានទាំងនោះដោយងាយស្រួល។ ក្នុងក្របខ័ណ្ឌនៃ

ការងារគណនេយ្យភាពសង្គមនេះ ប្រជាពលរដ្ឋត្រូវបានលើកទឹកចិត្តឱ្យធ្វើការត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពពាក់ព័ន្ធទាំងនោះ ហើយប្រជាពលរដ្ឋត្រូវធ្វើការពិភាក្សានូវចំណុចខ្វះខាតនានាពាក់ព័ន្ធនឹងការផ្តល់សេវា និងធ្វើការដោះស្រាយរួមគ្នាដោយសហគមន៍ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអង្គភាពផ្តល់សេវាពាក់ព័ន្ធនានា។ ការងារគណនេយ្យភាពសង្គមនេះត្រូវអនុវត្តរួមគ្នាដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាផ្នែកផ្គត់ផ្គង់ (Supply Side) ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិលជាផ្នែកតម្រូវការ (Demand Side) ក្នុងស្មារតីសហការគ្នា និងជួយផ្តល់យោបល់ឲ្យគ្នាប្រកបដោយលក្ខណៈស្ថាបនា។ រហូតមកដល់ពេលនេះ ការអនុវត្តការងារគណនេយ្យភាពសង្គមត្រូវបានអនុវត្តក្នុងខេត្តចំនួន ១៨ គ្របដណ្តប់លើស្រុកចំនួន ៩៨ និងឃុំចំនួន ៨២៧។

**-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !**

ទោះបីជាមានការខិតខំប្រឹងប្រែងពីរាជរដ្ឋាភិបាល ក្នុងការជំរុញឲ្យមានការចូលរួមពីអង្គការសង្គមស៊ីវិលក្នុងដំណើរការអភិវឌ្ឍសង្គមជាតិយ៉ាងណាក៏ដោយ ប៉ុន្តែនាពេលថ្មីៗកន្លងមកនេះ មានដៃគូអភិវឌ្ឍន៍ ក៏ដូចអង្គការសង្គមស៊ីវិលមួយចំនួនបានលើកឡើងអំពីក្តីព្រួយបារម្ភពាក់ព័ន្ធនឹងសិទ្ធិសេរីភាព ក្នុងការបំពេញការងាររបស់ខ្លួននៅតាមមូលដ្ឋាននានា ជាពិសេសនៅពេលមានការជួបជុំពិភាក្សាការងារជាមួយសហគមន៍ និងក្រុមប្រជាពលរដ្ឋ គឺតែងតែមានការតាមដាន និងការចាត់វិធានការរឹតបណ្តឹងនានាពីសំណាក់អាជ្ញាធរមូលដ្ឋានទៅលើសកម្មភាពជួបជុំរបស់អង្គការសង្គមស៊ីវិលទាំងនោះ។ ទន្ទឹមនេះ ក្រសួងមហាផ្ទៃ ក៏បានទទួលរបាយការណ៍ពីរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនបានលើកឡើងផងដែរថា អង្គការសង្គមស៊ីវិលមួយចំនួនពុំមានទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋាន ឬផ្តល់ព័ត៌មានដល់អាជ្ញាធរមូលដ្ឋានពេលធ្វើសកម្មភាពនៅក្នុងមូលដ្ឋានរាជធានី ខេត្តគោលដៅស្របតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ដោយតម្រូវឲ្យអង្គការសង្គមស៊ីវិល ជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ច ០៣(បី)ថ្ងៃ មុននឹងអនុវត្តសកម្មភាពរបស់ខ្លួន ប៉ុន្តែមិនតម្រូវឲ្យសុំការអនុញ្ញាតជាមុននោះឡើយ។ លើសពីនេះ អង្គការសង្គមស៊ីវិលខ្លះបានធ្វើសកម្មភាពញុះញង់ និងបំផុសបំផុលប្រជាពលរដ្ឋឲ្យធ្វើការតវ៉ាប្រឆាំងនឹងការអនុវត្តច្បាប់ ក្រោមហេតុផលនៃការតវ៉ាបញ្ហាដីធ្លី សិទ្ធិមនុស្ស ឬចុះបំពេញការងារនៅតាមមូលដ្ឋានដោយមិនបានសុំកិច្ចសហការជាមួយកម្លាំងមានសមត្ថកិច្ច ឬប្រឆាំងជាមួយនឹងកម្លាំងមានសមត្ថកិច្ចនៅពេលចុះពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធនានា។

ក្នុងបរិការណ៍នេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា វេទិកាថ្ងៃនេះនឹងធ្វើឲ្យរាជរដ្ឋាភិបាល ពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល មានការយល់គ្នាកាន់តែច្បាស់លាស់ថែមទៀត ដោយកំណត់បាននូវបញ្ហានានាដែលបានជួបប្រទះកន្លងមក និងស្វែងរកដំណោះស្រាយដើម្បីឈានទៅពង្រឹងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូយ៉ាងពិតប្រាកដ ហើយជាពិសេសសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនឹងចូលរួមអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងគោលបំណងលើកកម្ពស់នីតិរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ច

សង្គមកម្ពុជាឲ្យកាន់តែមានភាពរឹងមាំ និងមានការរីកចម្រើនបន្ថែមទៀត។ នៅក្នុងឱកាសដែលប្រទេសកម្ពុជាយើងកំពុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការធានាឲ្យការបោះឆ្នោតនេះប្រព្រឹត្តទៅដោយ សេរី ត្រឹមត្រូវ យុត្តិធម៌ និងមានសុវត្ថិភាព ដើម្បីបន្តជំរុញ និងលើកកម្ពស់ដំណើរការលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងនីតិរដ្ឋនៅកម្ពុជា។ ទន្ទឹមនេះ ខ្ញុំសូមអំពាវនាវដល់អាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធ ត្រូវតែខិតខំសម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់គណបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ ក្នុងការធ្វើសកម្មភាពដោយស្មើភាព ត្រឹមត្រូវ និងមិនលំអៀង ដើម្បីចូលរួមការបោះឆ្នោតជាតិនាពេលខាងមុខនេះ ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ និងសេចក្តីណែនាំរួមលេខ០១១ សណន ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ រវាងក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ជាមួយគ្នានេះដែរ ខ្ញុំសូមអំពាវនាវដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ត្រូវធ្វើសកម្មភាពប្រកបដោយភាពអព្យាក្រឹត្យ ស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលទាំងអស់ ដែលបានចូលរួមចំណែកយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជាកន្លងមក ដោយបានផ្តល់នូវការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសជាច្រើន ក្នុងកិច្ចការអភិវឌ្ឍន៍នៅព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនេះខ្ញុំសូមស្នើឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាតំណាងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល បន្តផ្តល់ការគាំទ្រ និងចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិឲ្យកាន់តែមានភាពរីកចម្រើន និងរុងរឿងដូចបណ្តាប្រទេសនានាលើសកលលោក។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គវេទិកាទាំងមូល សូមជួបប្រទះតែនឹងព្រះពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបើកវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលចាប់ពីពេលនេះតទៅ ។

សូមអរគុណ!